00748499

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**លេខ/No: D14/1/3**

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (**អបជ ០៣**)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**

**ចៅក្រម** Rowan DOWNING

**ចៅក្រម ន័យ ថុល**

**ចៅក្រម** Katinka LAHUIS

**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១១

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 10 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

---

**សាធារណៈ (សំណៅកោសលុប)**

**សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសេចក្តីប្រកាសព័ត៌មានជាសាធារណៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣**

---

**សហព្រះរាជអាជ្ញាអន្តរជាតិ**

ជា លាង

Andrew CAYLEY

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

Siegfried BLUNK

យូ ប៊ុនឡេង

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លើកទីពីរ ទៅសហចៅក្រមស៊ើបអង្កេត (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ”) ដើម្បីបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការសម្រាប់សំណុំរឿងនេះ[២]។

២. [redacted]

៣. នៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីប្រកាសព័ត៌មានដើម្បីជូនដំណឹងដល់សាធារណជនអំពីការងារដែលកំពុងដំណើរការ នៅក្នុងសំណុំរឿង ០០៣[៤]។

---

[១] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេច ស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ D14/1/1។

[២] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ស្តីពីការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លើកទី២ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ D1/1។

[៣] [redacted]

[៤] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១។ http://www.eccc.gov.kh/sites/default/files/media/ECCC_OCIJ_2_Feb_2011(Eng).pdf



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

៤. [redacted][៥]។

៥. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ[៦]។ ក្រោយពីបានចេញសេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការនេះរួចមក នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានចេញសេចក្ដីប្រកាសព័ត៌មានជាសាធារណៈ តាមវិធាន ៥៤ នៃវិធានផ្ទៃក្នុង ដែលសេចក្ដីប្រកាសនោះមានចំណងជើងថា "សេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ("សេចក្ដីប្រកាសព័ត៌មានជាសាធារណៈ")[៧]។ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា ខ្លួនចេញសេចក្ដីប្រកាសព័ត៌មាននេះដើម្បី "ធានាថាសាធារណជនបានទទួលព័ត៌មានគ្រប់គ្រាន់អំពីដំណើរការនីតិវិធីដែលកំពុងអនុវត្តនៅ អ.វ.ត.ក ហើយជាពិសេសគឺទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣[៨]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានប្រកាសថា ខ្លួន "នឹងស្នើសុំ" ឲ្យមានកិច្ចស៊ើបសួរបន្ថែមទៀត ពីព្រោះ "សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មិនត្រូវបានធ្វើការស៊ើបអង្កេតឲ្យបានពេញលេញនោះទេ"[៩]។

---

[៥] [redacted]

[៦] សេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់កិច្ចស៊ើបសួរ, លេខសំណុំរឿង ០០៣/០៧-០៩-២០០៩ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១, ឯកសារ D13។

[៧] សេចក្ដីប្រកាសព័ត៌មាន: សេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ មាននៅក្នុង http://www.eccc.gov.kh/sites/default/files/media/ECCC%20INT-OCP%209%20May%202011%20ENG_0.pdf.

[៨] សេចក្ដីប្រកាសព័ត៌មានជាសាធារណៈ: កថាខណ្ឌ ១។

[៩] សេចក្ដីប្រកាសព័ត៌មានជាសាធារណៈ: កថាខណ្ឌ ៦។

៦. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើការផ្សព្វផ្សាយអំពីការដកចេញព័ត៌មានរបស់ខ្លួន ក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ដោយដកចេញនូវផ្នែកមួយចំនួននៅក្នុងសេចក្តីប្រកាសព័ត៌មានជាសាធារណៈ ដែលមានព័ត៌មានទាក់ទងនឹង ១) ការបង្ហាញនូវមតិយោបល់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលតម្រូវឲ្យមានការស៊ើបអង្កេតតាមផ្លូវតុលាការ (“ព័ត៌មានប្រភេទក”) និង ២) សេចក្តីសង្ខេបនៃសំណើសុំឲ្យមានកិច្ចស៊ើបអង្កេត ដែលសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងនឹងស្នើឡើង (“ព័ត៌មានប្រភេទខ”) (“ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ”)[១០]។

៧. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត បានចុះបញ្ជីសេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាបង្គាប់ឲ្យដកព័ត៌មានចេញ[១១]។ សេចក្តីជូនដំណឹងនេះបានបញ្ជាក់ថា “សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ដីកាសម្រេចបង្គាប់មួយនេះ [ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ] គួរត្រូវបានព្យួរទុកសិន វៀរលែងតែអង្គបុរេជំនុំជម្រះចេញដីកាបង្គាប់ផ្សេងពីនេះ ដើម្បីរង់ចាំសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន”[១២]។

៨. បន្ទាប់ពីបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍របស់ខ្លួនរួចមក សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១។ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឲ្យអង្គបុរេជំនុំជម្រះពិចារណាទៅលើចំណុចដូចខាងក្រោម៖

---

[១០] ដីកាសម្រេចស្តីអំពីសេចក្តីសប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣ , ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារ D14។

[១១] សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង “ដីកាសម្រេចស្តីពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣” របស់សហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៧៤(២) និង ៧៥(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ D14/1។

[១២] សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង “ដីកាសម្រេចស្តីពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣” របស់សហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៧៤(២) និង ៧៥(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ D14/1 កថាខណ្ឌ ១។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * PRELIMINAIRE

"ក. ទាក់ទិននឹងផ្នែកនៃ ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ ទាក់ទងនឹងព័ត៌មានប្រភេទ ក នៃសេចក្ដីថ្លែងការណ៍ជាសាធារណៈ:

i. មេត្តាប្រកាសថា ដីកាបង្គាប់ឲ្យដកព័ត៌មានចេញនេះត្រូវបានចាត់ទុកជាមោឃៈតាំងពីដំបូង ដោយសារតែដីកានេះត្រូវបានចេញដោយគ្មានផ្អែកលើមូលដ្ឋានផ្លូវច្បាប់។

ii. ជាបន្ថែម និងជាជម្រើសមួយទៀត សម្រេចថា ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ គឺគ្មានសុពលភាពព្រោះដោយសារការបកស្រាយដោយភ័ន្តច្រឡំនូវច្បាប់ជាធរមាន និង/ឬ ដោយសារតែមានការរំលោភទៅលើឆន្ទានុសិទ្ធិ។

ខ. ទាក់ទិននឹងផ្នែកនៃ ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ ទាក់ទងនឹងព័ត៌មានប្រភេទ ខ នៃសេចក្ដីថ្លែងការណ៍ជាសាធារណៈ: មេត្តាអង្គបុរេជំនុំជម្រះសម្រេចថា ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ គឺគ្មានសុពលភាពទេ ព្រោះដោយសារការបកស្រាយដោយភាន់ច្រឡំ នូវច្បាប់ដែលនៅជាធរមាន និង/ឬ ដោយសារតែមានការរំលោភទៅលើឆន្ទានុសិទ្ធិ។

គ. ផ្អែកទៅលើ ផលប្រយោជន៍សាធារណៈនៅក្នុងបញ្ហាមួយនេះ និងដើម្បីជំរុញឲ្យមានជំនឿទុកចិត្តពីសាធារណជនបន្ថែមទៀតចំពោះដំណើរការប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័សរបស់តុលាការ៖

i. សូមមេត្តាអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាចេញផ្សាយជាសាធារណៈក្នុងពេលនេះ នូវច្បាប់ចម្លងដែលបានកោសលុបរួចនៃបណ្ដឹងឧទ្ធរណ៍នេះ ព្រមទាំង

ii. សូមឲ្យធ្វើការសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍នេះ ជាសាធារណៈ ដែលស្របតាមការអនុវត្តជាប្រចាំរបស់អង្គបុរេជំនុំជម្រះ[១៣]។

៩. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ គួរត្រូវបានច្រានចោលដោយផ្អែកលើមូលដ្ឋានមួយចំនួនរួមមាន៖ ទីមួយ ទាក់ទិននឹងផ្នែកមួយនៃដីកា ដែលនិយាយអំពីព័ត៌មានប្រភេទ ក នៅក្នុងសេចក្ដីប្រកាសព័ត៌មានជាសាធារណៈ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាបង្គាប់ឲ្យដកព័ត៌មានចេញគ្មានការគាំទ្រដោយបទប្បញ្ញត្តិណាមួយឡើយ ហើយដីកានេះត្រូវចាត់ទុកជាមោឃៈ*តាំងពីដំបូង*។ បន្ថែមពីលើនេះ និងម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានដោយភ័ន្តច្រឡំថា សហព្រះរាជអាជ្ញាអន្តរជាតិ មិន

---

[១៣] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៦៨។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

មានមូលដ្ឋានផ្លូវច្បាប់ណាមួយ ក្នុងការបង្ហាញមតិយោបល់ជាសាធារណៈនោះទេ។ ជាចុងបញ្ចប់សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ខ្លួនបានបំពេញកិច្ចក្នុងដែនអំណាច និងកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងច្បាប់។ ទាក់ទិននឹងផ្នែកនៃដីកាស្តីពីព័ត៌មានប្រភេទ ខ នៅក្នុងសេចក្តីប្រកាសព័ត៌មានជាសាធារណៈ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សេចក្តីប្រកាសនេះមិនបានលាតត្រដាងព័ត៌មានសម្ងាត់ណាមួយ ដែលប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយឡើយ ដូច្នេះសេចក្តីប្រកាសនេះមិនបានរំលោភលើវិធាន ៥៦(១) នៃវិធានផ្ទៃក្នុងនោះទេ។ ក្រៅពីមូលដ្ឋានទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ មិនមានសំអាងហេតុ ត្រូវបានធ្វើឡើងតាមតែអំពើចិត្ត និងគ្មានអានុភាពនោះទេ។

១០. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញដីកាសម្រេចព្យួរការអនុវត្ត ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ រហូតមានការសម្រេចចុងក្រោយលើបណ្តឹងឧទ្ធរណ៍ ("ដីកាសម្រេចព្យួរការអនុវត្ត")[១៤]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ដូចតទៅ៖

> "ព័ត៌មានដែលសហចៅក្រមស៊ើបអង្កេតស្នើឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើការដកចេញនោះត្រូវបានដកស្រង់នៅក្នុងដីកាសម្រេចចេញដោយសហចៅក្រមស៊ើបអង្កេត ដែលខ្លួនបានចាត់ថ្នាក់ឯកសារនោះថាសាធារណៈ[១៥]។ ហេតុដូច្នេះ ព័ត៌មាននៅតែបើកចំហដល់សាធារណជន បើទោះជាព័ត៌មាននោះត្រូវបាន "ដកចេញ" ដោយសហព្រះរាជអាជ្ញាក៏ដោយ។ ហេតុដូច្នេះ ការអនុវត្តដីកាសម្រេចដោយសហព្រះរាជអាជ្ញាដែលរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន នឹងមិនមានឥទ្ធិពលលើការរក្សាភាពសម្ងាត់នៃព័ត៌មាននេះទេ។ យ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា សិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការប្តឹងឧទ្ធរណ៍នៅចំពោះមុខខ្លួន នៅក្នុងសំណុំរឿងនាពេលនេះ នឹងមានលក្ខណៈជាទ្រឹស្តី ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែអនុវត្តដីកាសម្រេច មុនពេលមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ដោយបានទទួល

---

[១៤] ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣" ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ D14/1/2។

[១៥] ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ D14 កថាខណ្ឌ ២ និង ៣។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. PRÉLIMINAIRE

បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច និងដោយបានពិចារណាលើការពន្យារពេលដ៏ខ្លីមួយសម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការអនុវត្តដីកាសម្រេចនោះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាគឺជាផលប្រយោជន៍នៃយុត្តិធម៌ដែលអង្គបុរេជំនុំជម្រះអនុវត្តនូវយុត្តាធិការឥស្សរចិត្តរបស់ខ្លួន ដើម្បីព្យួរ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* នូវការអនុវត្តដីកាសម្រេច ដោយរង់ចាំការសម្រេចចុងក្រោយលើបណ្តឹងឧទ្ធរណ៍"[១៦]។

១១. គ្មានភាគីណាមួយបានដាក់ចម្លើយតបចំពោះបណ្តឹងឧទ្ធរណ៍នេះទេ។

## II. ច្បាប់ពាក់ព័ន្ធ

១២. មានការយោងទៅលើវិធាន ២១, ៣៥, ៣៨, ៥៤, ៥៥, ៥៦ និងវិធាន ៦៦ នៃវិធានផ្ទៃក្នុង។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១៣. ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ ត្រូវបានចេញកាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១។ បន្ទាប់ពីបានដាក់សេចក្តីជូនដំណឹងរួចមក សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ ដែលស្ថិតក្នុងអំឡុងពេលវេលាកំណត់ដូចមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុង។

១៤. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ដោយអនុលោមតាមវិធាន ៧៤(២) ឬជាជម្រើស អាចអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

---

[១៦] ដីកាសម្រេចព្យួរការអនុវត្ត កថាខណ្ឌ ៥។



PRE-TRIAL CH... E.C.C.C * C.E.T.C * ...PRÉLIMINAIRE

១៥. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងនូវទឡ្ហីករណ៍ដូចខាងក្រោម ទាក់ទិននឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ៖

> "អនុលោមតាមអនុវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងរាល់ដីកាសម្រេចទាំងអស់របស់សហចៅក្រមស៊ើបអង្កេត។ បើទោះបីជាបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងក៏ដោយ ក៏បណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបាន ព្រោះ៖
>
> ក. អនុលោមតាមអនុវិធាន ១(២) នៃវិធានផ្ទៃក្នុង សកម្មភាពរបស់សហព្រះរាជអាជ្ញាអាចធ្វើឡើងរួមគ្នា ឬធ្វើឡើងដោយសហព្រះរាជអាជ្ញាណាម្នាក់ ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីរ។
>
> ខ. ដោយសារតែមិនមានការចុះក្នុងឯកសារពីការខ្វែងគំនិតគ្នាណាមួយ ឬដោយហេតុនីតិវិធីស្តីពីការខ្វែងយោបល់គ្នា មិនបានផ្តួចផ្តើមឡើងដោយសហព្រះរាជអាជ្ញាណាមួយនោះ អនុវិធាន ៧១(៣)(ឃ) នៃវិធានផ្ទៃក្នុង មិនរារាំងដល់ការដាក់នូវបណ្តឹងឧទ្ធរណ៍នេះឡើយ។
>
> គ. ការអនុវត្តការដាក់សំណុំឯកសារដោយសហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត តែមួយរូបនោះ ត្រូវបានទទួលស្គាល់ថា មានសុពលភាពក្នុងករណីនេះ។
>
> ឃ. បើទោះបីជាអង្គបុរេជំនុំជម្រះ មិនយល់ស្របជាមួយនឹងការលើកឡើងនៅក្នុងអនុកថាខណ្ឌ ក ដល់ គ ខាងលើក៏ដោយ ក៏អង្គបុរេជំនុំជម្រះ គួរតែយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋាននៃអនុវិធាន ២១(១) នៃវិធានផ្ទៃក្នុង៖
>
> i. ដីកាបង្គាប់ឱ្យដកព័ត៌មានចេញ បានចេញបង្គាប់ដល់សហព្រះរាជអាជ្ញាអន្តរជាតិតែមួយរូបប៉ុណ្ណោះ ហើយដីកានេះសំដៅដោយផ្ទាល់ចំពោះតែផលប្រយោជន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងនាមជាមន្ត្រីឯករាជ្យមួយរូបនៅក្នុងតុលាការ។ ការបដិសេធសិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបែបនេះ គឺមិនស្របទៅតាមគោលការណ៍ជាសារវ័ន្តនៃយុត្តិធម៌ សច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី ប្រកបដោយតម្លាភាព ដូចមានចែងក្នុងអនុវិធាន ២១(១) នៃវិធានផ្ទៃក្នុងឡើយ។

ii. ដីកាបង្គាប់ឲ្យដកព័ត៌មានចេញបានលើកឡើងចំណុចសំខាន់ៗជាសារវ័ន្ត ដែលមិនទាន់បានធ្វើការជំនុំជម្រះដោយអង្គបុរេជំនុំជម្រះនៅឡើយ។ សេចក្តីសម្រេចលើអង្គសេចក្តីរបស់អង្គបុរេជំនុំជម្រះ នឹងផ្តល់នូវគោលការណ៍ណែនាំចំពោះសហចៅក្រមស៊ើបអង្កេត ក៏ដូចជាភាគីនានា។ ដូច្នេះសេចក្តីសម្រេចនេះនឹងជំរុញឲ្យមានសច្ចភាពផ្លូវច្បាប់ កាន់តែខ្លាំងឡើងថែមទៀត ព្រមទាំងពង្រឹងនូវជំនឿទុកចិត្តរបស់សាធារណជនចំពោះស្ថាប័នមួយនេះ”[១៧]។

១៦. អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា នៅពេលដែលពិនិត្យទៅលើបរិបទ ព្រមទាំងពិចារណាជាមួយនឹងវិធាន ៧៣ នៃវិធានផ្ទៃក្នុង វាបានបង្ហាញយ៉ាងច្បាស់ថា វិធាន ៧៤(២) បានប្រមើលមើលទុកជាមុននូវសិទ្ធិរបស់សហព្រះរាជអាជ្ញា ក្នុងការប្តឹងឧទ្ធរណ៍ទៅលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលពាក់ព័ន្ធទៅនឹងកិច្ចស៊ើបអង្កេតព្រហ្មទណ្ឌ។ ចរិតលក្ខណៈនៃដីកាដែលរងការជំទាស់ គឺមិនមែនជាដីកាដែលទាក់ទិនទាំងស្រុងតែទៅលើកិច្ចស៊ើបអង្កេតព្រហ្មទណ្ឌប៉ុណ្ណោះនោះទេ ដីកានេះក៏ទាក់ទងផងដែរទៅលើសកម្មភាពរបស់មន្ត្រីតុលាការ។ ហេតុដូច្នេះការប្តឹងឧទ្ធរណ៍ផ្អែកតាមវិធាន ៧៤(២) នឹងតំណាងឲ្យការរួមបញ្ចូលគ្នាដោយខុសឆ្គង នូវស្ថានភាពអង្គហេតុ ជាមួយនឹងបទប្បញ្ញត្តិច្បាប់ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានពឹងផ្អែក សម្រាប់បង្កើតជាយុត្តាធិការ ក្នុងការប្តឹងឧទ្ធរណ៍នេះ។

១៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុង ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចង្អុលបង្ហាញមូលដ្ឋានច្បាប់ សម្រាប់ការប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបង្គាប់ឲ្យភាគីណាមួយ ឬមន្ត្រីរបស់តុលាការណាម្នាក់ ធ្វើការដកចេញនូវព័ត៌មាននោះឡើយ។ នេះគឺជាលើកដំបូងបំផុត ដែលសហចៅក្រមស៊ើបអង្កេតបានចេញដីកាដែលមានលក្ខណៈបែបនេះ ដូច្នេះអង្គបុរេជំនុំជម្រះត្រូវតែពិនិត្យជាដំបូងទៅលើមូលដ្ឋានច្បាប់ដែលជាមូលដ្ឋាននៃការចេញដីកាសម្រេចមួយនេះ ហើយអង្គបុរេ

[១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

ជំនុំជម្រះនឹងត្រូវពិនិត្យថាតើមូលដ្ឋាននេះអាចបង្កើតឱ្យបានជាសិទ្ធិដើម្បីប្តឹងឧទ្ធរណ៍ តាមច្បាប់ជាធរមានបាន ដែរឬយ៉ាងណា។

១៨. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មូលដ្ឋានច្បាប់សម្រាប់ការចេញដីកាបង្គាប់ឱ្យដកព័ត៌មានចេញ គឺជាវិធាន ២១, ៥៤, ៥៥, ៥៦, និងវិធាន ៦៦ នៃវិធានផ្ទៃក្នុង។

១៩. បន្ទាប់ពីបានវិភាគទៅលើវិធានទាំងអស់នេះនៃវិធានផ្ទៃក្នុង នៅក្នុងដីកាបង្គាប់ឱ្យដកព័ត៌មានចេញ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញទាក់ទងដល់ព័ត៌មានប្រភេទ ក ថា៖

> "អនុលោមតាមវិធាននេះ [វិធាន ៥៤] សហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិត្រឹមតែផ្តល់នូវការសង្ខេប នៃការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ តែប៉ុណ្ណោះ ដោយពុំមានសិទ្ធិធ្វើការបង្ហាញមតិយោបល់ជាសាធារណៈទាក់ទងនឹង "ឧក្រិដ្ឋកម្មដែលតម្រូវឱ្យមានការស៊ើបសួរ" នោះឡើយ ព្រោះនេះជាកិច្ចការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត (វិធាន ៥៥.១)"[១៨]។

២០. សហចៅក្រមស៊ើបអង្កេតសង្កត់ធ្ងន់ថា វិធាន ៥៤ អនុវត្តបានតែនៅក្នុងដំណាក់កាលស៊ើបអង្កេតបឋមតែប៉ុណ្ណោះ ហើយសហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា សហព្រះរាជអាជ្ញាអន្តរជាតិមិនមានមូលដ្ឋានផ្លូវច្បាប់ ដើម្បីចេញផ្សាយសេចក្តីថ្លែងការណ៍ជាសាធារណៈឡើយ៖

> វិធាន ៥៤ ចែងបន្ថែមថា "*លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាអាចកែតម្រូវរួមគ្នាដោយផ្ទាល់ ឬ តាមរយៈផ្នែកកិច្ចការសាធារណៈនូវព័ត៌មានមិនពិត ឬព័ត៌មាននាំឱ្យមានការភ័ន្តច្រឡំ នៅពេលដែលសំណុំរឿងនេះ ស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម*"។
>
> ទោះបីជាយ៉ាងនេះក៏ដោយ ការស៊ើបអង្កេតបឋម (វិធាន ៥០) បានបញ្ចប់ជាមួយនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមកសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន

---

[១៨] ដីកាបង្គាប់ឱ្យដកព័ត៌មានចេញ កថាខណ្ឌ ៤។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

៥៣.១ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ រួចទៅហើយ[19]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ មិនមានមូលដ្ឋានផ្លូវច្បាប់ដើម្បីចេញ "សេចក្តីប្រកាសពត៌មានជាសាធារណៈ ប្រភេទក នោះទេ។

២១. បន្ថែមលើនេះ ពាក់ព័ន្ធទៅនឹងព័ត៌មានប្រភេទ "ខ" សហចៅក្រមស៊ើបអង្កេតបានរកឃើញថា៖

"...សហព្រះរាជអាជ្ញាបានរំលោភលើវិធាននៃការរក្សាការសម្ងាត់ ដោយបានជូនដំណឹងដល់សាធារណជនជាមុន និងយ៉ាងលម្អិតអំពីការណ៍ដែលខ្លួន "*ស្នើសុំដល់សហចៅក្រមស៊ើបអង្កេតឱ្យ*" អនុលោមតាមវិធាន ៦៦.១ នៃវិធានផ្ទៃក្នុង"[20]។

២២. សហចៅក្រមស៊ើបអង្កេតបានសម្រេចជាចុងក្រោយថា៖

"អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតសម្រេចបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិធ្វើការផ្សព្វផ្សាយអំពីការដកចេញពីសេចក្តីប្រកាសព័ត៌មាននូវព័ត៌មានប្រភេទ "ក" និង "ខ" ដែលបានផ្សព្វផ្សាយនៅលើគេហទំព័រ អ.វ.ត.ក ក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃនៃការដាក់ឯកសារ"[21]។

សំអាងហេតុសម្រាប់ការសម្រេចនេះមានដូចតទៅ៖

"ដោយយោងទៅលើអនីត្យានុកូលភាពនៃព័ត៌មានប្រភេទ "ក" និងការរំលោភលើវិធាននៃការរក្សាការសម្ងាត់ទាក់ទងនឹងព័ត៌មានប្រភេទ "ខ" សហព្រះរាជអាជ្ញាអន្តរជាតិត្រូវធ្វើការផ្សព្វផ្សាយអំពីការដកសេចក្តីប្រកាសព័ត៌មានដែលបានធ្វើ នៅក្នុងទម្រង់ដូចដែលខ្លួនបានចេញសេចក្តីប្រកាសព័ត៌មាននេះ។ ការណ៍នេះធ្វើឡើងដើម្បីធ្វើឱ្យមានទំនុកចិត្តឡើងវិញនៅក្នុងនីត្យានុកូលភាព និងការសម្ងាត់នៃការស៊ើបសួរ និងត្រូវធ្វើឡើងក្នុងរយៈពេលដ៏ខ្លីខាងមុខ"[22]។

---

[19] ដីកាបង្គាប់ឱ្យដកព័ត៌មានចេញ កថាខណ្ឌ ៥ ដល់ ៦។

[20] ដីកាបង្គាប់ឱ្យដកព័ត៌មានចេញ កថាខណ្ឌ ៧។

[21] ដីកាបង្គាប់ឱ្យដកព័ត៌មានចេញ កថាខណ្ឌ ៩។

[22] ដីកាបង្គាប់ឱ្យដកព័ត៌មានចេញ កថាខណ្ឌ ៨។



PRE-TRIAL CH... E.C.C.C. * C.E.T.C. ...PRÉLIMINAIRE

២៣. ពាក់ព័ន្ធទៅនឹងការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងព័ត៌មានប្រភេទ "ក" អង្គបុរេជំនុំជម្រះយល់ឃើញថា ការអានលម្អិតទៅលើវិធាន ៥៦ និងវិធាន ៦៦ នៃវិធានផ្ទៃក្នុង គាំទ្រដល់ការរកឃើញនៅក្នុងកថាខណ្ឌ ៦ នៃដីកាបង្គាប់ឲ្យដកព័ត៌មានចេញ ដែលថា "សហព្រះរាជអាជ្ញាអន្តរជាតិមិនមានមូលដ្ឋានផ្លូវច្បាប់ណាមួយ ក្នុងការបង្ហាញនូវព័ត៌មានប្រភេទ "ក" នៃសេចក្តីប្រកាសព័ត៌មាននោះឡើយ" ដោយហេតុថា កាតព្វកិច្ចរបស់សហព្រះរាជាអាជ្ញា អនុលោមតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុង អាចអនុវត្តបានយ៉ាងច្បាស់លាស់តែនៅក្នុងអំឡុងពេលនៃការស៊ើបសួរ *បឋម* តែប៉ុណ្ណោះ និងមិនអាចពន្លាតការអនុវត្តនេះមកនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ *តាមផ្លូវតុលាការ* ដែលសេចក្តីថ្លែងការណ៍ជាសាធារណៈត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលមួយនេះ។

២៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដោយអនុលោមតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុង កាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការជូនដំណឹងទៅកាន់សាធារណជន អំពីកិច្ចដំណើរការនីតិវិធីដែលកំពុងប្រព្រឹត្ត ត្រូវបានកំហិតមកត្រឹមតែ (១) ការផ្តល់ឲ្យនូវការសង្ខេបសត្យានុម័តនៃព័ត៌មាន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ និង (២) ការកែតម្រូវព័ត៌មានមិនត្រឹមត្រូវ ឬព័ត៌មានដែលនាំឲ្យមានការភ័ន្តច្រឡំ *ដរាបណាសំណុំរឿងស្ថិតនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរបឋម*នៅឡើយនោះ[២៣]។

២៥. បន្ថែមលើនេះ[២៤] វិធាន ៥៦ នៃវិធានផ្ទៃក្នុង ចែងថា ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ មានតែសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ដែលមានការទទួលខុសត្រូវ និងអំណាចផ្លូវច្បាប់ ដើម្បីធានាថាព័ត៌មានចាំបាច់ ត្រូវបានផ្តល់ទៅឲ្យសាធារណជន៖

---

[២៣] បើទោះជាសេចក្តីថ្លែងការណ៍ជាសាធារណៈនេះ ត្រូវបានធ្វើឡើងដោយអនុលោមតាមមាត្រា ១២១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដោយ ក៏សហព្រះរាជអាជ្ញា [អន្តរជាតិ] នៅតែត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវ ដែលចែងថា ការប្រកាសសេចក្តីថ្លែងការណ៍ជាសាធារណៈ អាចត្រូវបានអនុញ្ញាតឱ្យធ្វើបានតែនៅពេលណា "ដែលសហព្រះរាជអាជ្ញាយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ គឺជាព័ត៌មានមិនពិត" តែប៉ុណ្ណោះ។

[២៤] មាត្រា ១២១ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា "ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន"។

00748511



១. ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់។

២. ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអាច៖

ក. តាមរយៈផ្នែកកិច្ចការសាធារណៈ ផ្ដល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿង ដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឲ្យសាធារជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬដើម្បីកែតម្រូវព័ត៌មានមិនពិត ឬ ព័ត៌មាននាំឲ្យមានការភ័ន្តច្រឡំ។ និង

ខ. ក្នុងកាលៈទេសៈពិសេស ផ្ដល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬអ្នកដទៃទៀតដែលមិនមែនជាភាគីឲ្យចូលរួម ដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ ដោយការចូលរួមនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹងរបស់ខ្លួន និងបន្ទាប់ពីបានសួរយោបល់របស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។ ក្នុងករណីមិនគោរពទៅតាមលក្ខខណ្ឌណាមួយ ដែលសហចៅក្រមស៊ើបអង្កេតតម្រូវ វិធាន ៣៦ ដល់ ៣៨ ត្រូវយកមកអនុវត្ត។

២៦. វិធាន ៣៥ ចែងថា:

១. "អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ *រួមទាំងបុគ្គលដែល៖*

ក. ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ [...]។

២. នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច៖

ក. ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។

ខ. ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឲ្យដឹងប្រាកដថាតើមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ឬ




អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
E.C.C.C. * C.E.T.C.
PRÉLIMINAIRE

[...]

៦. រាល់សេចក្តីសម្រេចដែលធ្វើឡើងក្រោមវិធាននេះ អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ [..]"។

២៧. ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតសម្រេចថា សហព្រះរាជអាជ្ញាអន្តរជាតិបានបំពេញកិច្ចមួយចំនួនដោយគ្មានមូលដ្ឋានផ្លូវច្បាប់ ហើយបានរំលោភបំពានបន្ថែមទៀតទៅលើវិធានស្តីអំពីការសម្ងាត់ ដូចមានចែងនៅក្នុងវិធាន ៥៦ (១) នៃវិធានផ្ទៃក្នុង។ មូលដ្ឋានផ្លូវច្បាប់នៅក្នុងការចេញដីកាសម្រេចនេះ មិនឃើញមាននៅក្នុងវិធានផ្ទៃក្នុង ដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីកាសម្រេចរបស់ខ្លួននោះទេ ប៉ុន្តែមូលដ្ឋានផ្លូវច្បាប់នេះឃើញមាននៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ វិធានផ្ទៃក្នុង ៣៥ (១) ដែលចែងស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ប្រើពាក្យថា "រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម" និងមិនកំហិតត្រឹមតែ អំពើនានាដែលមានរៀបរាប់យ៉ាងជាក់លាក់នៅក្នុង ផ្នែកនេះនៃវិធាននេះឡើយ។ អំពើទាំងនេះ គឺជាឧទាហរណ៍មួយចំនួននៃប្រភេទអំពើនានា ដែលស្ថិតនៅក្នុងចង្កោមនៃកិច្ចទាំងឡាយណា ដែលអាចបង្កើតបានជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះបាន។ ការបំពេញកិច្ចដោយគ្មានមូលដ្ឋានផ្លូវច្បាប់ និងការរំលោភបំពានលើការ រក្សាការសម្ងាត់ ដូចបានប្បញ្ញត្តិដោយច្បាប់ ត្រូវតែជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់ អង្គជំនុំជម្រះដោយចេតនា។ សហចៅក្រមស៊ើបអង្កេត ដែលទទួលខុសត្រូវលើកិច្ចស៊ើបសួរតាមផ្លូវតុលាការ មានសិទ្ធិចេញដីកាសម្រេច ពាក់ព័ន្ធនឹងការរំលោភបំពានលើការរក្សាការសម្ងាត់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សូម្បីតែការរំលោភបំពាននោះគឺជាការគិតថាមានក៏ដោយ ពីព្រោះថា សហចៅក្រមស៊ើបអង្កេតអាចចាត់ការជាមួយបញ្ហានេះជាបន្ទាន់ ដូចបានប្បញ្ញត្តិនៅក្នុងវិធាន ៣៥ (២) នៃវិធានផ្ទៃក្នុង។

២៨. វិធាន ៣៥ (៦) នៃវិធានផ្ទៃក្នុង ចែងអំពីសិទ្ធិក្នុងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ។ ដូច្នេះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអាចទទួលយកបាន ដោយអនុលោមតាមវិធានផ្ទៃក្នុងមួយនេះ ។ ដោយបានពិចារណាលើសារតារនៃដីកាសម្រេចនេះ ដែលមើលទៅឃើញថាបានធ្វើឡើងដោយផ្អែកលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង នោះមិនមានជាបញ្ហាទេថាតើសហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យបំពេញកិច្ចនេះតែម្នាក់ឯង ឬយ៉ាងណានៅក្នុងការដាក់បណ្តឹងឧទ្ធរណ៍នោះ។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

## IV. បទដ្ឋាននៃការពិនិត្យពិចារណា

២៩. ដូចដែលបានរកឃើញរួចមកហើយ អង្គបុរេជំនុំជម្រះត្រូវពិចារណាថាតើសហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុ ឬបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន នៅក្នុងការចេញដីកាបង្គាប់ឱ្យដកព័ត៌មានដែរឬទេ[២៥]។

## V. សេចក្តីពិចារណាលើអង្គសេចក្តី

៣០. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសដោយប្រកាសថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនមានមូលដ្ឋានច្បាប់ណាមួយសម្រាប់ការបញ្ចេញយោបល់របស់ខ្លួនបានឡើយ ហើយសហព្រះរាជអាជ្ញាលើកជាទឡ្ហីករណ៍ទៀតថា ខ្លួនបានបំពេញកិច្ចនៅក្នុងក្របខ័ណ្ឌអំណាច និងកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់។ ទាក់ទងទៅនឹងផ្នែកនៃដីកាសម្រេចដែលដោះស្រាយលើព័ត៌មានប្រភេទ "ខ" នៃសេចក្តីថ្លែងការណ៍ជាសាធារណៈនោះ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា វាមិនមានព័ត៌មានសម្ងាត់ណាមួយ ដែលប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយឡើយ ហេតុដូច្នេះ វាមិនបំពានទៅលើវិធាន ៥៦ (១) នៃវិធានផ្ទៃក្នុងនោះទេ។

៣១. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការផ្តល់មតិយោបល់ជាសាធារណៈ ឬក្នុងការបង្ហាញអំពីមតិយោបល់សាធារណៈ ពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ដែលបំពេញដោយសហចៅក្រមស៊ើបអង្កេតនោះ មិនមានចែងនៅក្នុងច្បាប់ឡើយ។ ផ្ទុយទៅវិញ សិទ្ធិបែបនេះត្រូវបានកំហិតដោយបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលសហព្រះរាជអាជ្ញាមានកាតព្វកិច្ច

[២៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ (អបជ៦៩) ប្រឆាំងទៅនឹងដីកាសម្រេចលើសំណើលើកទីពីររបស់លោក នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥) ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារលេខ D384/5/2 កថាខណ្ឌ ១៧ ដល់ ១៩, កថាខណ្ឌ ៣៨ និងកថាខណ្ឌ ៤៣ ដល់ ៤៥។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · CHAMBRE PRÉLIMINAIRE

ត្រូវគោរពតាមលក្ខខណ្ឌកំហិតទាំងនេះ។ យុត្តិកម្មសម្រាប់ទង្វើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួននោះ មិនអាចធ្វើឱ្យទង្វើរបស់គាត់ត្រឹមត្រូវ ហើយ មិនអើពើចំពោះឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញផ្សាយព័ត៌មាននៅក្នុងដំណាក់ កាលនៃកិច្ចស៊ើបសួររបស់តុលាការបានឡើយ។ ខណៈពេលដែលអង្គបុរេជំនុំជម្រះយល់ស្របជា គោលការណ៍ និងដូចដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិជាធរមាននានា ដែលថា ការអនុញ្ញាត ឱ្យសាធារណជនទទួលបាននូវព័ត៌មានស្ដីពីកិច្ចដំណើរការនីតិវិធី គឺជាសិទ្ធិជាសារវ័ន្តដើម្បីទទួលបាន ការជំនុំជម្រះក្ដីដោយយុត្តិធម៌នោះ[២៦] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ជាក់លាក់នានា ចែងយ៉ាងច្បាស់អំពីថាតើបុគ្គលណាដែលមានសិទ្ធិដើម្បីធ្វើសេចក្ដីថ្លែងការណ៍ជា សាធារណៈស្ដីពីកិច្ចដំណើរការនីតិវិធីដែលកំពុងប្រព្រឹត្តិទៅ ថាតើសេចក្ដីថ្លែងការណ៍នោះនឹងត្រូវធ្វើ ក្នុងកាលៈទេសៈបែបណា និងត្រូវធ្វើនៅក្នុងដំណាក់កាលណានៃកិច្ចដំណើរការនីតិវិធីជាក់លាក់នានា។ ការគោរពតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ទាំងនេះគឺជាកាតព្វកិច្ច។

៣២. ពាក់ព័ន្ធទៅនឹងចំណុចនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកជា ទឡ្ហីករណ៍ថា "បញ្ជីដែលមាននៅក្នុងចំណុច "ខ" មិនអាចត្រូវបានពិចារណាថាជាអ្វីក្រៅពីសេចក្ដី សង្ខេបជាទូទៅមួយ"[២៧] នោះ អង្គបុរេជំនុំជម្រះសូមរំឭកដល់សហព្រះរាជអាជ្ញាអន្តរជាតិថា វិធាន ផ្ទៃក្នុង មិនតម្រូវ ឬចងកាតព្វកិច្ចដល់សហព្រះរាជអាជ្ញា ឱ្យផ្ដល់សេចក្ដីសង្ខេបព័ត៌មានបែបនេះទៅឱ្យ សាធារណជនឡើយ។ មិនថាកម្រិតនៃភាពលម្អិតនៅក្នុងបញ្ជីនោះយ៉ាងណានោះទេ អង្គបុរេជំនុំជម្រះ សូមរំឭកដល់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះការកត់សម្គាល់មុនៗរបស់ខ្លួន ជាពិសេសពាក់ព័ន្ធ ទៅនឹងភាពសម្ងាត់នៃកិច្ចដំណើរការនីតិវិធីទាក់ទងទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ[២៨]។

---

[២៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨។

[២៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤០។

[២៨] សេចក្ដីសម្រេចលើសំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់ លើបណ្ដឹងឧទ្ធរណ៍ អបជ២៤ និងអបជ២៥ ឯកសារលេខ D164/4/3 ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២00៩ កថាខណ្ឌ ៥។ សូមមើលផងដែរនូវសេចក្ដីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើង វិញនូវសេចក្ដីសម្រេចទាក់ទងនឹងសំណើសុំឱ្យមានសវនាការ ដើម្បីពិនិត្យបណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អបជ២៤ និងអបជ២៥ ឯកសារលេខ D164/4/9 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២00៩ កថាខណ្ឌ ៣0។



* PRE-TRIAL C... * E.C.C.C * C.E.T.C * ...PRÉLIMINAIRE

៣៣. បន្ថែមលើនេះ ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ព័ត៌មានពាក់ព័ន្ធនឹងកិច្ចស៊ើបសួររបស់តុលាការគួរត្រូវបានចេញផ្សាយនោះ សហព្រះរាជអាជ្ញាគួរបានស្នើសុំសហចៅក្រមស៊ើបអង្កេតជាមុនដើម្បីឱ្យខ្លួនអាចធ្វើដូច្នេះបាន។ ប្រសិនបើគាត់បានស្នើសុំ ហើយសំណើរបស់គាត់ត្រូវបានបដិសេធ នោះគាត់អាចប្ដឹងឧទ្ធរណ៍សេចក្ដីសម្រេចបដិសេធនោះមកអង្គបុរេជំនុំជម្រះបាន។ ការដែលសហព្រះរាជអាជ្ញាអន្តរជាតិមិនបានស្នើសុំសហចៅក្រមស៊ើបអង្កេត ហើយបានធ្វើការផ្សព្វផ្សាយព័ត៌មានដោយខ្លួនឯង គឺមានន័យថា គាត់មិនបានអនុវត្តតាមកាតព្វកិច្ចនៃការរក្សាភាពសម្ងាត់ទេ ដូចដែលសហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់យ៉ាងត្រឹមត្រូវ។ ដូច្នេះ ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិដកព័ត៌មានចេញវិញ មានយុត្តិកម្មត្រឹមត្រូវ។

៣៤. មុននឹងពិចារណាបន្ថែមទៀតទៅលើប្រយោគចុងក្រោយនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខណៈពេលដែលចៅក្រមចំនួនបីរូបនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាបង្គាប់ឱ្យដកព័ត៌មានគួរត្រូវបានតម្កល់ទាំងស្រុង ហើយបណ្ដឹងឧទ្ធរណ៍នេះគួរត្រូវបានបដិសេធចោលនោះ ចៅក្រមចំនួនពីររូបទៀតនៃអង្គបុរេជំនុំជម្រះ ផ្ដល់សំអាងហេតុ និងស្នើឡើងថា ដីកាបង្គាប់គួរត្រូវបានតម្កល់ជាផ្នែកតែប៉ុណ្ណោះ ដោយហេតុថា សេចក្ដីសម្រេចរបស់ដីកាបង្គាប់នោះ នៅតែមិនមានអានុភាពដដែល ហើយដូច្នេះ ជាលទ្ធផល បណ្ដឹងឧទ្ធរណ៍នេះគួរត្រូវបានទទួលយកដោយផ្នែកផងដែរ។ ដោយអនុលោមតាមមាត្រា ១៤ (២) នៃច្បាប់ស្ដីអំពីការបង្កើត អ.វ.ត.ក និងវិធាន ៧៧ (១៤) នៃវិធានផ្ទៃក្នុង យោបល់ដោយឡែក និងដោយផ្នែកទាំងនេះត្រូវភ្ជាប់មកជាមួយនឹងសេចក្ដីសម្រេចមួយនេះ និងត្រូវជូនដំណឹងដល់ភាគីទាំងអស់។ បន្ថែមលើនេះ ដោយអនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង ហើយដោយសារថាអង្គបុរេជំនុំជម្រះ មិនទទួលបាននូវមតិគាំទ្រភាគច្រើនពីចៅក្រមចំនួន ៤ (បួន) រូបទេនោះ ដីកាបង្គាប់ឱ្យដកព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតត្រូវមានអានុភាព។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. * C.E.T.C. PRÉLIMINAIRE

00748516



## VI. សេចក្តីសម្រេច

### ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ ÷

១. ជាឯកច្ឆន្ទ យល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

២. ជាឯកច្ឆន្ទ ប្រកាសថា អង្គបុរេជំនុំជម្រះមិនទទួលបានសំឡេងគាំទ្រពីអង្គចៅក្រមចំនួនបួនរូប ដើម្បីសម្រេចបណ្តឹងឧទ្ធរណ៍លើអង្គសេចក្តីបាននោះទេ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដីកាបង្គាប់ឱ្យដកព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតត្រូវមានអានុភាព។

ភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១

ប្រធាន អង្គបុរេជំនុំជម្រះ

ប្រាក់ គិមសាន Rowan DOWNING ន័យ ធុល Kantinka LAHUIS ហួត វុទ្ធី

00748517



**យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ទាក់ទងនឹង និយតភាពនៃដីកាបង្គាប់ឱ្យដកព័ត៌មាន៖**

យើងយល់ឃើញថា ការប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើឱ្យបែកធ្លាយឯកសារសំងាត់ដែលកំពុងស្ថិតក្នុងការស៊ើបសួរនោះ ជាកំហុសដែលសហព្រះរាជអាជ្ញាអន្តរជាតិបានបង្កើតឡើងដោយផ្ទាល់។ ការដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងវិញនូវព័ត៌មាន ដែលខ្លួនបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិដកចេញពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈ នៅក្នុងដីកាសម្រេចរបស់ខ្លួននោះ គឺ ដើម្បីចង្អុលបង្ហាញឱ្យបានច្បាស់ពីចំណុចដែលត្រូវដក តែប៉ុណ្ណោះ។ ហេតុដូច្នេះ យើងយល់ឃើញថា ការដែលសហចៅក្រមស៊ើបអង្កេតសម្រេចចេញដីកាបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើការផ្សព្វផ្សាយអំពីការដកចេញសេចក្តីប្រកាសព័ត៌មានប្រភេទ “ក” និង “ខ” របស់ខ្លួន នោះ គឺ ជាការចាំបាច់។

ភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១

ហួត វុទ្ធី ន័យ ថុល ប្រាក់ គឹមសាន

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00748518



**យោបល់របស់ចៅក្រម Rowan DOWNING និងចៅក្រម Katinka LAHUIS ទាក់ទងនឹងនិយតភាព នៃដីកាបង្គាប់ឲ្យដកព័ត៌មាន៖**

១. សហចៅក្រមស៊ើបអង្កេតបានភ័ន្តច្រឡំខ្លួនឯងទៅលើស្ថានភាពនេះ ដោយខ្លួនបានបង្ហាញជាសាធារណៈជាថ្មីម្តងទៀតនូវព័ត៌មានសម្ងាត់ជាច្រើនផ្នែក ដែលព័ត៌មាននោះត្រូវបានសហចៅក្រមស៊ើបអង្កេតខ្លួនឯងបានបង្គាប់ឱ្យដកចេញ។ ដោយបានធ្វើដូច្នេះ ដីកាបង្គាប់របស់ខ្លួនមិនមានអានុភាពជាក់ស្តែងអ្វីឡើយ ដោយហេតុថាការផ្សាយព័ត៌មាននោះ ត្រូវឱ្យគេយល់ថា ជាការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការធ្វើដូច្នេះ ប៉ុន្តែជាលទ្ធផលការធ្វើបែបនេះ បណ្តាលឱ្យដីកាបង្គាប់ដកព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតមិនមានសុពលភាព និងគ្មានអានុភាព។

២. នៅក្នុងស្ថានភាពបែបនេះ ការបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាំងស្រុង និងការបង្គាប់ឱ្យដកព័ត៌មាននោះ នឹងមិនមានន័យអ្វីឡើយ ដោយហេតុថា អានុភាពនៃការធ្វើបែបនេះ នឹងប្រាសចាកចេញពីខ្លឹមសារនៃដីកាបង្គាប់ឱ្យដកព័ត៌មាននោះ ពីព្រោះថា ព័ត៌មាននោះបានស្ថិតនៅក្នុងបណ្តាញសាធារណៈរួចទៅហើយ ។ យើងជាចៅក្រមដែលបានចុះហត្ថលេខាខាងក្រោមនេះពិចារណាឃើញថា វានឹងជាផលប្រយោជន៍យុត្តិធម៌ល្អបំផុត ក្នុងការទទួលយកបណ្តឹងឧទ្ធរណ៍ដោយផ្នែក ត្រង់ផ្នែកនៃសេចក្តីសម្រេចនៃដីកាបង្គាប់ឱ្យដកព័ត៌មាន ដែលមិនមានអានុភាព។

ភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១

**Rowan DOWNING** **Katinka LAHUIS**